# ការសម្ភាសន៍ជាលើកទីពីររបស់អ្នកមីង ប៉ូច ខាន់

កៈ អ្នកដែលសម្ភាសន៍ឈ្មោះ ញ៉ែមសុគន្ធា ខៈ អ្នកដែលត្រូវគេសម្ភាសឈ្មោះ ប៉ូច ខាន់

## ការសង្ខេបលើកទីពីររបស់អ្នកមីង ប៉ូច ខាន់

អ្នកមីងប៉ូច ខាន់ នៅក្នុងការសំភាសន៍ជាលើកទី២គាត់បានប្រាប់ថាគាត់មិនដែលបានទទួលការសិក្សាទេព្រោះតែគាត់ឈឺរហូត។ អ្នកមីងបានរៀបការហើយមានកូនប្រុសស្រីហើយសព្វថ្ងៃកូនរបស់គាត់បានរៀបការជិតអស់ហើយហើយសព្វថ្ងៃគាត់រស់នៅជាមួយចៅហើយស្វាមីហើយកូនពៅជិតភ្ជាប់ពាក្យ។អ្នកមីងបានឆ្លងកាត់របបសង្គ្រាមទាំងពីររបបហើយគាត់បានប្រាប់ថានៅក្នុងសង្គ្រាមលន់ នល់ គាត់បានឃើញទំលាក់គ្រាប់បែកហើយគាត់បានរត់ចូលក្នុងត្រង់សេដើម្បីការពារខ្លួនរបស់គាត់ពីគ្រាប់បែក។ក្នុងរបបប៉ុល ពតគឺគាត់ត្រូវធ្វើការយ៉ាងលំបាក កាត់ស្មៅក្នុងទឹក ហើយការហូបចុកគឺលំបាកបានអ្វីហូបគឺត្រូវលាក់លៀមព្រោះខ្លាចគេយកទៅសម្លាប់ ពេលទៅធ្វើការគឺចាប់បានក្តាមខ្យងហើយយកទៅដុតហូបហើយអ្វីៗគឺមិនបានហូបស្រួលទេទាល់តែលួច។ ឥឡូវអ្នកមីងបានរស់នៅជាមួយចៅនឹងប្តីយ៉ាងសុខសប្បាយ។

ក ៖

ជាដំបូងនេះខ្ញុំសូមថ្លែងអំណារគុណដល់អ្នកមីងដែលឲ្យខ្ញុំសម្ភាសអំពីជីវប្រវត្តិរបស់អ្នកមីងជាលើកទី 2នាងខ្ញុំឈ្មោះញ៉ែម សុគន្ធាជាអ្នកសម្ភាសន៍អំពីជីវិតរបស់អ្នកមីងនេះជាលើទី 2។ ពួកយើងសម្ភាសន៍គឺនៅក្នុងភូមិដំណាក់សង្កែ ឃុំព្រែកកំពឹសស្រុកកណ្តាលស្ទឹងខេត្តកណ្តាលប្រទេសកម្ពុជា!!! ពួកយើងសម្ភាសន៍នៅក្នុងខែឧសភាឆ្នាំ 2018។អញ្ជឹងអើរអ្នកមីងយើងចង់ឲ្យឈ្មោះអ្នកមីងឈ្មោះពេញរបស់អ្នកមីងវិញម្តងទៀត ឈ្មោះអ្វីដែរ?

ខៈ ប៉ូវ ខាន់!!

កៈ

ចាំ!!អ្នកមីងសម្រាប់ចូលដល់ការសិក្សារបស់អ្នកមានដោយសារពេលមុនអ្នកមីងបានរៀបរាប់

ពីជីវិតក្រុមគ្រួសាររបស់អ្នកមីងបានច្រើនហើយពីការសិក្សារបស់អ្នកវិលវិញណាស់អ្នកមីងបានរៀនដល់ថ្នាក់ទីប៉ុន្មានដែរអ្នកមីង??

ខ៖ ខ្ញុំមិនដែលបានរៀនផង!!!

ក៖ អត់ដែលបានរៀនសូត្រតែម្តងអ្នកមីង?

ខ៖ អត់!!!

ក៖ ហើយ និយាយទៅអក្ខរកម្ម??

ខ៖ អត់បានដឹងទេ!!!ពីតូចនិងឈឺពេកឈឺភ្នែកឈឺតែភ្នែក!!

ក៖ យ៉ាងម៉េចអាចនឹងអញ្ជើញអ្នកមីង?

ខ៖ មិនដឹងជាយ៉ាងម៉េច!!!

ក៖ វាឡើងក្រហមតែម្តងអ្នកមីងហោ?

ខ៖ នឹងហើយ!!!គ្រូមើលឡើងមើលអត់ជា!!

ក៖ តើអ្នកលេងឥឡូវមើលមានស្រវាំង អីដែរឬអត់?

ខ៖ ហ៊ឺ!! ស្រវាំង ហៀរ
តែទឹកភ្នែកទីតើ!!!ក៖ហ្ហ៎!!!ខ៖នឹងឃើញទេភ្នែកមួយចំហៀងជាដែទឹកភ្នែកទេតើ!!!
នេះឡើងកន្ទុយថ្លែន

ក៖ ហើយអ្នកមីងឯទៅពេទ្យឲ្យគេពិនិត្យមើលដែរឬទេ?

ខ៖ អត់ដែលទៅផង៕

ក៖
ភ្នែកសំខាន់ណាស់អ្នកមីង!!តែបើសិនជាពេលក្រោយឈឺខ្លាំងអ្នកមីងនេះគួរតែអោយគេពិនិត្យទៅកុំឲ្យវាមានបញ្ហាកើតឡើងពេលខាងក្រោយ
អញ្ចឹងណាស់!!!តែដល់ពេលទុកទៅវាលែងមានអីដែរអ្នកមីងឈណោះ?

ខ៖ ហ្នឹងហើយ!!

ក៖ អញ្ចឹងហោងហើយអ្នកីង!!!

ខ៖ អត់អី!!

ក៖ ចាំ,!!

ខ៖ ពេលនៅពីតូចឈឺក៏ធ្វើដែរនឹង!! មើលអស់មួយកំនរដែលនឹងភ្នែក!!

ក៖ ចាំ!!

ខ៖ មូលអស់ប៉ុន្មានហ្ហ៎ អស់ 5 ជីងណោះ!!ខ្ញុំណាស់!!

ក៖ យកទៅគ្រូទៅអីអញ្ចឹងទៅអ្នកមីងណោះ??

ខ៖ ហ្នឹងហើយ។

ក៖ ចាំ
អ្នកមានដូចជាសព្វថ្ងៃថាអត់បានរៀនអត់បានចូលសាលាចុះតើអ្នកមីងមានបានចេះអានអក្សរពីកអាអ្វីដែលអត់អ្នកមីង?

ខ៖  អត់ អត់សូវចេះទេ!!

ក៖ សរសេរអក្សរអ្វីក៏អត់ចេះដែរមែនទេ?

ខ៖ ហ្នឹងហើយ!!

ក៖ ដែលបានមានអត់ដែលចេះភាសាខ្មែរតែមានលួចរៀនរៀនភាសាបរទេសអីទេអ្នកមីង?

ខ៖ អត់មានទេ។

ក៖ អត់ដែល?

ខ៖ អត់ដែល!!

ក៖ អញ្ចឹងពេលហ្នឹងដោយសារការឈឺបានអត់បានចូលរៀនៗចឹងអ្នកមបឹងមែននោះ?

ខ៖ ហ្នឹងហើយ!!

ក៖ តែឪពុកម្តាយរបស់អ្នកមីងចង់អោយអ្នកមីងទៅដែរមែនទេ?

ខ៖ ចង់អោយកូនរៀនដែរប៉ុន្តែកូនវាឈឺពេក!!

ក៖ ចាំ!! អ្នកមីងពេលរៀននិងនៅអំពៅព្រៃឬក៏មកនៅតាវេសហ្នឹងហើយ?

ខ៖ នៅអំពៅព្រៃ!!

ក៖ ហើយអញ្ចឹងអ្នកមីង
ពេលនៅពីក្មេងមានមិត្តភក្ដិអ្វីច្រើនលេងជាមួយដែរឬទេដែរឬទេអ្នកមីង?

ខ៖ មាន!!

ក៖ អ្នកមីងឥឡូវមិត្តភ័ក្រ្តរបស់អ្នកមីងនៅរាប់អានទាល់តែឥឡូវហ្នឹងដែរឬទេ?

ខ៖ បែកគ្នាអស់ហើយ!!!

ក៖ ទៅណាអស់ហើយ?

ខ៖ ដឹងគេមានប្ដីទៅណាទៅណាទៅណីអ្នកខ្លះងាប់អ្នកខ្លះអីអស់ហើយ!!!

ក៖ តែឥឡូវនៅមានអ្នកដែលនៅរស់អត់ដែនទំនាក់ទំនងអីទេហោ៎?

ខ៖ អត់ដែលជួបគ្នាទេ។

ក៖ ចា៎!!អញ្ចឹងបើសិនជាអ្នកមិនមានរឿងអ្វី!!

ខ៖ បានគេខ្លាំងនៅទីនេះនៅម្ដុំ យើងអស់ដែលបាន នៅក្របៅអាចម៍កុក
យើងអត់ដែលទៅដែលបានជួបគ្នាទេ!!

ក៖
អញ្ចឹងអ្នកមីងសព្វថ្ងៃបើមានរឿងអ្វីដែលចង់ពិភាក្សាពិភាក្សាជាមួយប្ដីនិងប្រពន្ធហ្នឹងហើយអ្នកមីងហោ៎???

ខ៖ ហ្នឹងហើយ!!!

ក៖
មិត្តផងមិត្តភក្ដិផងប្ដីប្រពន្ធផងអញ្ចឹងដែរ!!អញ្ចឹងអ្នកមីងពេលសម្រាប់វ័យក្មេងដែលមានការស្រមៃធំឡើងចង់ធ្វើអ្វីដែរអត់អ្នកមីង?

ខ៖ គ្មាន ស្រមៃចង់ធ្វើអីផងមានតែធ្វើស្រែធ្វើចម្ការនិងឯង
ចុះបើយើងគ្មានចេះអ្វីផងស្រម៉ៃចង់ធ្វើអ្វី!!!

ក៖
ក្រែងលោរចេះតែគិតច្រើនៗចឹងទៅអ្នកមីងណាស់!!តែដោយសារជំងឺធ្វើអោយអ្នកមីងអាកខានអញ្ចឹងទៅណាស់!!!

ខ៖ ហ្នឹងហើយ!!មានស្រមៃនោះចិត្តចង់ថាចេះអ៊ីចឹងទៅយើងមានមុខចង់រិមុខរបរអ្វីរកស៊ីចឹងទៅណាស់ទៅណាស់តែដល់ពេលយើងអញ្ចឹងអី
អត់ចេះអក្សរអត់ចេះអីមានតែអញ្ចឹងមានតែធ្វើស្រែធ្វើចម្ការអី!!

ក៖ អ្នកមីងដើមអ្វីដែលនៅក្នុងចម្ការបន្លែអីទេ?

ខ៖ ដើមតែនេះនឹង!!

ក៖ ដើមស្អីគេបន្លែមានឆៃថាវឬក៏អ្វីអត់?

ខ៖ ដើមឆៃថាវដាំតាំងពីនៅជាមួយតាជាមួយយាយដីណោះ!! ក៖ចាំ!!
ខ៖ដាំត្រកួនដាំស្ពៃចង្កឹះស្ពៃអីយើងនឹង!!!

ក៖ ពេលមុនសំបូរអញ្ចឹងទៅអ្នកមីងណោះ??

ខ៖ នឹងហើយចេះតែដើមទៅនៅទួលក្រោយផ្ទះក្រោយអ្វីដឹងណាស់!!ហ្នឹងហើយ!!

ក៖ ពេលនិងទាំងគ្រួសារឬក៏តែម្នាក់ជាមួយលោកពូ?

ខ៖ ជាមួយតែម្តាយនិងជាមួយបងប្អូន!!

ក៖ បានយកទៅលក់ដែរអ្នកមីងណោះ?

ខ៖ ចាំ!!
ដាំអញ្ចឹងទៅដុះដល់ពេលដកពេលដល់អញ្ចឹងទៅបងថ្លៃយកទៅលក់ទៅណាស់!!ក៖ចាំ!!!ខ៖ឪពុកនិងយកទៅលក់ទៅ!!

ក៖ អ្នកមានមានដែលអាកូនសល់តូចៗនិងមីនដែលយកទៅធ្វើជ្រក់អីដែលឬទេ?

ខ:៖ធ្វើតើ!!អាគេធីរតូចតូចហ្នឹង!!ក៖ចាំ!!ខ៖ហ្នឹងហើយធីរទៅម្តាយខ្ញុំក៏ធ្វើអញ្ចឹងទៅគាត់ច្រកដាក់ក្នុងស្បោងៗអញ្ចឹងទៅអោយទូដាក់អាកូនកញ្ច្រែងទូចដើរលក់!!!

កៈ ហ្នឹងហើយពេលនៅក្មេងៗតែអញ្ចឹង
អ្នកមីងពេលខ្ញុំនៅពីក្មេងបើសិនជាខ្ញុំអោយខ្ញុំដើរលក់អីវ៉ាន់ចង់ខ្មាសគេមិនដឹងអីទេខ្ញុំមានអារម្មណ៍ថាខ្លាចតែខ្ញុំលក់មិនដាច់ហេតុដល់ពេលបែបហ្នឹងទៅខ្មាស់គេអើយខ្មាស់!!

ខៈ បើឃើញគេគ្នាច្រើនអញ្ចឹងទៅ ឃើញអុំអំ មីងមីងអីគ្នាច្រើនទូលចូលហើយ។

កៈ ចាំ!!!

ខៈ ហៅចូលទៅមួយនាក់មួយថង់មួយនាក់មួយថង់ហើយ!!ដល់ពេលអញ្ចឹងទៅអស់!!!

កៈ ចាំ!!! អ្នកមីងឥឡូវចូលដល់នេះវិញម្តងប្តីអ្នកមីងដំបូងយ៉ាងម៉េចបានជួបស្វាមីអ្នកមីង?

ខៈ គាត់បែកពីប៉ុលពត។

កៈ  អ្នកមិនបែកពីប៉ុលពតហើយប៉ុន្មានឆ្នាំបានរៀបអាពាហ៍ពិពាហ៍ជាមួយនឹងលោកពូ?

ខៈ បែកពីប៉ុលពតបានតែប៉ុន្មានខែនិង!!!

កៈ ហើយរៀបការយកតែម្តង?

ខៈ
ចាំ!!!ចាស់ៗគាត់ស្តីយកកាលពេលហ្នឹងយើងមិនទាន់មានអកកេះឯណាមានតែធុងសាំងហ្នឹង!!

កៈ ហើយវ៉ៃ ធុងសាំងរាំតែម្តងមែនទេ?

ខៈ នឹងហើយ!!!វ៉ៃ ធុងសាំងរាំតើ!!

កៈ រាំចេះតែរាំរាំទៅវ៉ៃមិនដឹងចេញជាស្អីគេទេ!!!

ខៈ ហ្នឹងហើយតាំងចងដៃតែស្រូវហ្នឹង!!!កៈចាំ!!!ខ ៈហ្នឹងហើយស្រូវអង្ករគ្មានទាន់មានអ្វីផង!!

កៈ តែពេលហ្នឹងក៏នៅសល់ខ្លះខ្លះដែរអ្នកមីងមែនទេ?

ខៈ មានតើ!!

កៈ ចាំ!! ដែរមានគេចងមសដែរមែនទេអ្នកមីង?

ខៈ បងប្អូនខ្លះគេងមានគេចងទៅខ្លះ 5ហ៊ុន ខ្លះ៥ជីអញ្ចឹងទៅ!!

កៈ ចាំ,!! ហើយអ្នកមីងរៀបការជាមួយនឹងលោកពូបែកពីប៉ុលពត 1979អ្នកមីងណោឈះ?

ខ៖ ចាំ!!!

ក៖ អ្នកមីងនអាយុប៉ុន្មានរៀបការពេលនឹង?

ខ៖ 18!!!

ក៖ 18ហ្នឹងអញ្ចឹងអ្នកមីងពេញចឹងនៅក្នុងប៉ុលពតហើយនិងលន់ណុលនោះ??

ខ៖ នឹងហើយ ប៉ុលពត!!

ក៖ ស្អីក៏ដឹងដែរអ្នកមាន!!!

ខ៖ ចំបក់អាពត ធ្វើការនៅកន្លែងទៅកាត់ស្បែកទៅកាប់អ្វីមានអាទឹកត្រឹមត្រឹមនេះត្រឹមត្រឹមកត្រឹមត្រឹមទ្រូង!!!

ក៖ មានឈ្លើងទេអ្នកមីង?

ខ៖ ឈ្លើងក៏ឈ្លើង អាឈ្លើងទាមទៅនាំគ្នាស្រែកប្រកាច់ពេញតែទឹកនិងទៅ!!ពស់កពស់!!

ក៖ ហើយពស់មិនមែនសាហាវឯណាអ្នកមីងមែនទេ?

ខ៖ អាបពស់ពស់ព្រលិតពស់ខ្មៅអីប៉ុន្តែខ្មៅនិងវាមិនសូវទេច្រើនតែអាពស់ព្រលិតអាពស់ឈើ។ហើយអាទំនប់ទួលក្រសាំងមិនសុទ្ធតែរែក។

ក៖ ហ្នឹងហើយ។

ខ៖ សុទ្ធតែចែកម៉ែតគ្នារែក។

ក៖ អញ្ចឹងអ្នកមីងសុទ្ធតែជាអ្នករែកមួយហ្នឹងទេហ៎?

ខ៖ ចាំ!!!

ក៖ អាផ្លូវយើងទួលក្រសាំងយើងបុកទៅវៀតណាមនឹងណាស់?

ខ៖ ហ្នឹងហើយ និងសុទ្ធតែរែកទេតើ!!!

ក៖ ចាំ!! ម៉ាស្បាខ្ញុំផុតសម្ភាសន៍លោកពូមួយនោះអ្នកទៅកោះគណាស់អ្នកមីងរែកអាហ្នឹងដែរ!!!

ខ៖ ហ្នឹងហើយ!!

ក៖ ថាសុទ្ធតែរ៉េតបង្គីដែកនិងអ្នកមីងហ៎?

ខ៖ ហ្នឹងហើយគ្រាន់តែគេដាក់ភ្លាម គេដាក់ភ្លើងគេដាក់អីព្រោងព្រាតអីៗចឹងទៅ ប៉ុន្តែពេលដល់ធ្វើការរាវសប្បាយម្យ៉ាងដែរ!!

ក៖ មិនដឹងសប្បាយឯណាទេនៅពេលជំនាន់ប៉ុលពត ភ័យចង់តែងាបភ័យឡើងរាកអាចមន៍!!

ខ៖ ពេលដែរទេគេអោយមកវែក មកវែកអញ្ចឹងទៅ!!គេឲ្យទៅស្ទូងទៅ ទៅស្ទូងទៅ!!

ក៖ចាំ!!ឥឡូវឈប់សិនកុំទាន់អាលនិយាយពីប៉ុលពតនីតិរឿងអំពីប្តីសិនពេលបែកពីប៉ុលពត ហើយពេលនឹងអ្នកលេងស្រលាញ់គ្នាពីពេលមុនដែរឬទេ?

ខ៖ មិនដែលជួបគ្នាផង!!

ក៖ ហើយចេះតែព្រមស្រលាញ់តែខ្ញុំឆ្ងល់ណាស់នេះ!!!

ខ៖ ចាស់ៗហ្នឹង!!

ក៖ អង្គរចាស់ៗជំនាន់មុនចេះតែចាប់ជល់គ្នាតែម្តង!!

ខ៖ ហ្នឹងហើយ!!

ក៖ អ្នកខ្លះមិនដែលស្គាល់គ្នា!!

ខ៖ បងប្អូនហ្នឹង!!!ម៉ែហើយនឹងម៉ែកំពតបង្កើត!!!

ក៖ ហ្ហ៎!!!ម៉ែឪខ្ញុំវិញឪពុកហើយនិងឪពុកបងប្អូនបង្កើត ហើយគាត់ជីដូនមួយ!!

ខ៖ ម៉ែអើយនឹងម៉ែ ម៉ែហៅម៉ែបងប្អូនបង្កើត!!!

ក៖ ចាំ!! ហើយអ្នកមីងហើយស្គាល់គ្នាតាំងពីក្មេងមកមែនទេ?

ខ៖ អត់ដែរស្គាល់ទេ!!

ក៖ ឪយ៉ាងម៉េចបានអត់បានស្គាល់បងប្អូនជីដូនមួយ?

ខ៖
ចុះបើយើងនៅតូចតូចពេលយើងនេះទៅគាត់ទៅធ្វើនេះតាំងពីប៉ុននេះ!!!ប៉ុណ្ណឹងហិ!!ក៖ចាំ!!!ខ៖ ទៅធ្វើទាហ៊ានហិ!!!

ក៖ ងាប់ហើយទៅធ្វើទាហ៊ានតាំងពីកុមារហ្នឹង!!

ខ៖ នឹងអើយទៅបែករហូតតាំងពី បែកអាពតមក
គាត់មកដែរប៉ុន្តែគាត់តែគ្រាន់តែយើងមិនដែលស្គាល់។

ក៖ ហ្នឹងហើយដូចជាមិនចាប់អារម្មណ៍អញ្ចឹងទៅអ្នកមីងណោះ!!

ខ៖ បានចាប់អារម្មណ៍និងណាស់!!

ក៖ ហ្នឹងហើយ!! ហើយផ្ទះជិតគ្នាដែរទេអ្នកមីង?

ខ៖ ផ្ទះនៅឆ្ងាយពីគ្នាដែរ ផ្ទះខ្ញុំនៅអញ្ចាំងផ្ទះគាត់នៅឯជើងអញ្ចឹងទៅ។

ក៖ ហាកហ៎ចា៎!!

ខ៖ នៅភូមិទូលខុសគ្នាអញ្ចឹងទៅណាខ្ញុំនៅទូលខាងណាស់គាត់នៅទូលខាងនោះអញ្ចឹងទៅ!!

ក៖ ចា៎ អ្នកមីង!!

ខ៖ ហ្នឹងហើយ!!

ក៖ឯអ្នកមានពេលរៀបការនិងរៀបការបែកពីរជំនាន់ប៉ុលពតការហើយគេមានអោយថ្លៃចំនួនអីអត់អ្នកមីងបណ្ដាការខ្មែរយើងបណ្ដាការ?

ខ៖ មាននេះឯណា !!

ក៖ អត់អោយអ្វីទាំងអស់មែនទេ?

ខ៖ មានស្អីទេ!!

ក៖ ដោយសារពេលបែកមកម្នាក់ម្នាក់ដៃទទេទាំងអស់មែនទេអ្នកមីង?

ខ៖ មកគ្រាន់តែនិយាយអញ្ចឹងមាននំគម នំអន្សមអីបន្តិចបន្តួចអីអញ្ចឹងទៅហ្នឹង!!

ក៖ ចា៎!! ហេតុពេលនឹងដូចរបៀបការចូលស្ដួរបានប៉ុន្មានថ្ងៃរៀបការអ្នកមីង!!

ខ៖ មានស្អី!!!ទទួលបានកន្លះខែ!!

ក៖ មណ្ឌលក្មេងសម័យឥឡូវក្មេងឥឡូវគេត្រូវតែសិក្សាអំពីគ្នា!!

ខ៖ អត់ទេឥឡូវចូលយាងពីឥឡូវហ្នឹងអញ្ចឹងទៅទុក្ខទាល់តែមួយឆ្នាំអីអញ្ចឹងទៅ!!

ក៖ ហ្នឹងហើយ!!

ខ៖ ហ្នឹងហើយ!!

ក៖ ដល់ពេលមុនអត់បានទេតែមួយខែកន្លះខែនិងគឺថា!!

ខ៖
មុនអត់បានទេចាស់ៗទាំងបួនចាស់ៗគាត់មានអត់ឯណាតែគ្រាន់តែថាបែបនេះអញ្ចឹងទៅនាំគ្នាអាត្បាល់កិនយើងនឹង!!ក៖ចាំ!!ខ៖មិនកិនៗហើយជាន់អញ្ចឹងទៅប្រវាស់ដៃគ្នាស្រីស្រីហើយនិងប្រុសនាំគ្នាកំលោះក្រមុំនិងមិនចេះជួយគ្នាទៅ!!ក៖ចាំ!!!ខ៖ហ្នឹងហើយ។ដូចថាបែបនេះដូចគ្នាយើងបែកគ្នាប្រវាស់យកដៃគ្នាគេកាប់អុសទៅកាប់អ្វីក៏យើងបែកគ្នាដែរ។

ក៖ ចាំ!! អញ្ចឹងសុទ្ធតែស្គាល់គ្នាមែនទេអ្នកមីង?

ខ៖
ហ្នឹងហើយទៅប៉ុន្មានរទេះទៅកាប់ពីបីថ្ងៃអញ្ចឹងមកយកមកគរដល់ពេលការម្នាក់ទៀតធ្វើអញ្ចឹងទៀតទៅ។

ក៖ ចាំ!!អញ្ចឹងសុទ្ធតែជួយគ្នាទៅវិញទៅមកទាំងអស់?

ខ៖ ហ្នឹងហើយជួយគ្នាទៅមកទៅមកហ្នឹង!!

ក៖ ពេលជំនាន់មុននោះគេថាចូលព្រៃរកផ្លែឈើនិងអ្នកមីងណេះ??

ខ៖ ហ្នឹងហើយ!!

ក៖ មិនសូវបានដាំប៉ុន្មានទេ!! ភាគច្រើនណាស់!!

ខ៖ ហ្នឹងហើយគេតាមចំការចំការនៅ កាលនៅទីនោះនៅទីនោះសុទ្ធតែដាំជាចម្ការ!!

ក៖ ចាំ!! អញ្ចឹង អ្នកមីងគ្មានបណ្តាការអ្វីទេ???

ខ៖ អត់មានទេ!!

ក៖
អញ្ចឹងអ្នកមីងពេលលោកពូចូលដណ្តឹងអ្នកមីងមានចាប់ផ្តើមស្រលាញ់គាត់ខ្លះហើយឬនៅ?

ខ៖ អត់!!

កៈ
អត់ដឹងស្រឡាញ់យ៉ាងម៉េចបងមិនទាន់ចេះស្រលាញ់ទេការហើយគ្មានចាស់ៗថាអោយដេក
គេអោយហូបបាយចេកអីនោះនាំគ្នាទៅលេងទល់ណាទល់ណី!!ចាស់ៗអង្គុយតាមចាំដែរហើយ!!

កៈ ចាស់ៗជំនាន់មុននិង !!

ខៈ នឹងហើយ។

កៈ អ្នកមាននេះតែម្តងដូចចូល ការហើយជាមួយលោកពូបានកូនប៉ុន្មាននាក់អ្នកមីង?

ខៈខ្ញុំបានកូន 5។

កៈ 5 នាក់!! ស្រីប៉ុន្មានប្រុសប៉ុន្មាននាក់អ្នកមីង?

ខៈ ប្រុស 2 ស្រី 3។

កៈ ចាំ!! អ្នកមីអាចប្រាប់ឈ្មោះកូនកូនៗ ហ្វូប្រាប់ឈ្មោះប្ដី?

ខៈ ឈ្មោះហេង។

កៈ ហ៊ុលហេង?

ខៈ ហាយ ហេង!!

កៈ ហាយ ហេង? ខៈចាំ!! កៈ
អញ្ចឹងឥឡូវកូនសិនកូនបងគេរហូតដល់ពៅគាត់ឈ្មោះអ្វីខ្លះអ្នកមីង?

ខៈ អាពៅហ៉េ??

កៈ តាំងពីបងគេហាំ!!

ខៈ បងហ៉េ??កៈចាំ!!ខៈឈ្មោះហៀង ហេងហៀង។

កៈ ឈ្មោះហេងហៀង បន្ទាប់មកទៀត?

ខៈ បន្ទាប់មកទៀតឈ្មោះនី ហេង នី!!ហេងចាន់នី ហេងចាន់ណា ហេងឋានៈ
អីហ្នឹងហេងសំណាង។

កៈ អញ្ចិងទៅគេឈ្មោះសំណាង!! ហ្នឹងពេលគេហៅអ្នកមីង?

ខ៖ មិនមែនទេអានេះអាបង!!

ក៖ អញ្ចឹងនេះគឺជាបងគេទេហ៎?

ខ៖ ចា៎!!!

ក៖ ហ្នុ៎ អញ្ចឹងកូនអ្នកមីងត្រដឹកត្រដឹកដែលឬទេ?

ខ៖ ហ្នឹងហើយ។

ក៖ អញ្ចឹងអ្នកមីងសម្រាប់កូនអ្នកមីងមីងមានអោយគាត់ទៅរៀនទាំងអស់គ្នាទេអ្នកមីង?

ខ៖ រៀនទេតើ!!!

ក៖ ចា៎,!!!និយាយទៅ!!

ខ៖ រៀននៅទីនេះនៅសាលាយើងនេះ!!

ក៖ សាលារៀនវត្តកែវមុនីនេះ?

ខ៖ ហ្នឹងហើយ!!វត្តគោករលួសយើងនឹង!!

ក៖ ចា៎!!
អ្នកមីងពួកគាត់ទាំងអស់សុទ្ធតែបានរៀនបានខ្ពស់ខ្ពស់ដែរឬអត់បានរៀនដល់វិទ្យាល័យដែរឬទេ?

ខ៖ រៀនបានតែបន្តិចដែរហ្នឹងកូនកូនរបស់ខ្ញុំ អោយអត់ទៅ!!

ក៖ យ៉ាងម៉េចអ្នកមីងបានជាឲ្យកូនរៀនតែបន្តិចអញ្ចឹង?

ខ៖
រៀនបានតែបន្តិចចង់យើងអត់មកដល់ពេលរៀនទើបតែបានប៉ុន្នានទេនៅពោធិ៍សាត់ទៅធ្វើការនៅពោធិ៍សាត់ហ្នូ!!ក៖ចា៎!!ខ៖ទៅដាំល្ហុងខ្វង អាអីស្អី ដើមល្ហុងហ្នុ៎!!

ក៖ អា ល្ហុងរឿងយកមកញាំផ្លែ?

ខ៖ មិនមែនទេ!!!

ក៖ ល្ហុងច្បុងមែនទេ?

ខ៖ អា ល្ហុង!!

ក៖ ល្អមានតែល្ហុងយើងញ៉ាំផ្លែ ហើយមានអ្វីទៀតទៅអ្នកមីង?

ខ៖ អាល្ហុងគេបានធ្វើប្រេងធ្វើអ្វី!!!

ក៖ ហ្នឹងហើយល្ហុងច្បងហ្នឹងហើយ!!

ខ៖ អាផ្លែ!!

ក៖ ផ្លែមូលមូល ចង្កោមហ្នឹងអ្នកមីងណោះ??

ខ៖ ហ្នឹងហើយ!!

ក៖ ពេល និងអ្នកមីងទៅធ្វើអោយក្រុមហ៊ុនគេឬក៏ឬក៏ដាំដោយខ្លួនឯង?

ខ៖ ទៅដាំឲ្យក្រុមហ៊ុនគេស៊ីប្រាក់ខែហ្នឹង!!!

ក៖ ឥឡូវគេនៅតែដាំដុះទេអ្នកមីង?

ខ៖ ឥឡូវមិនដឹងទេ លេងហើយលេងហើយឥឡូវហ្នឹង លែងបានហើយឈប់យូរហើយ!!!

ក៖ អ្នកមីងដឹងទេថាគេដាំដុះយកធ្វើអី យកធ្វើស្អីគេខ្លះអាណឹង?

ខ៖ អត់ដឹង!!!យកទៅធ្វើស្អីគេខ្លះទេ!!

ក៖ តែស្រួលថៃទាំទេតើអ្នកមីងមិនពិបាកអ្វីទេមែនទេ?

ខ៖ ហ្នឹងហើយ!!!ដាក់ទៅឆាប់ណាស់!!

ក៖ ហ្នឹងហើយមែន!!

ខ៖ គេ បាញ់ជីបាញ់អីថែមទៅឆាប់ធំណាស់!!

ក៖ ដោយសារពេលខ្ញុំនៅក្មេងអា ផ្លែមួយហ្នឹង ផ្លែចោលតែវាក៏មានដែរ!!

ខ៖ ហ្នឹងហើយ។

ក:តាមរបងតាមអ្វីៗចឹងណាស់!!តែគ្រាន់តែឥឡូវអត់ឃើញទេ គេដាំ!!

ខ៖ អាមួយនឹងផ្លែដូចជាផ្លែដូងដែរ!!!

កៈ តែវាទូចទូចនិងអ្នកមីង?

ខៈ ហ្នឹងហើយវាតូចតូច!!!

កៈ ហ្នឹងហើយ។

ខៈ សាច់ក្នុងរបស់វាដូចជាផ្លែដូងអញ្ចឹង!!

កៈ ចាំ!! ហ្នឹងហើយខ្ញុំចាំហើយផ្លែល្ហុងច្បងនឹងនោះ!!ហើយពេលហ្នឹង ទៅធ្វើការ
អោយគេនៅទីនោះនៅពោធិ៍សាត់ឲ្យគេប៉ុន្មានខែអ្នកមីង?

ខៈ ទៅរាប់ឆ្នាំ មួយឆ្នាំជាងឯណោះ។

កៈ ទៅទាំងកូនទាំងអស់តើមែនទេ?

ខៈ ដឹងហើយទៅទាំងអស់គ្នាទៅមានបានរៀនអ្វីរៀនបានតើថ្នាក់ទីប៉ុន្មាន!! តែថ្នាក់ទី 3 ទី 4!!

ក :ហ៊ឺ!!!
ហើយដល់ពេលបែបនឹងពួកគាត់ធ្វើការអីគេដែរអ្នកមិនដល់ពេលគាត់មានបានតិចៗចឹង?

ខៈ អត់មានបានធ្វើការអ្វីទេធ្វើបានតែសំណង់ហើយនិងរោងចក្រហ្នឹង!!!!

កៈ ហ្ហ៎ អញ្ចឹងកូនស្រីបានធ្វើការរោងចក្រដែរអ្នកមីងណោះ?

ខ :កូនខ្ញុំធ្វើការរោងចក្រដែរទេតើ!!

កៈ ចាំ!!! តើឥឡូវកូនទាំងប្រាំអ្នកណាគេរៀនបាន ហាអ្នកណាគេរៀបការខ្លះហើយអ្នកមីង?

ខៈ រៀបការអស់ហើយហ្នឹង!!

កៈ ទាំងអស់តែម្តង?

ខ :នៅសល់តែអាពៅមួយទេទៅភ្ជាប់ពាក្យទេថ្ងៃទី 24ហើយ!!

កៈ អីយ៉ាស ចំអាយុប៉ុន្មានអ្នកមីងពៅគេ?

ខៈ ពៅគេ 21ហើយ។

កៈ 21 តែរៀបការអស់ហើយមែនទេអ្នកមីង?

ខ :ហ្នឹងហើយ!!

កៈ ខ្ញុំ 28រកដៃគូមិនឃើញផង!!អត់ត្រូវចិត្តតែម្តងអ្នកមីង
ចាំមើលសិនចាំមើលឲ្យបានច្រើនសិនចាំរៀបការ!!

ខៈ កូនរបស់ខ្ញុំមានប្រពន្ធមានប្តីសុទ្ធតែនៅឆ្ងាយឆ្ងាយ!!

កៈ ឥឡូវបែកផទៈទៅនៅឆ្ងាយឆ្ងាយអស់?

ខៈ ហ្នឹងហើយទៅនៅឆ្ងាយឆ្ងាយទាំងអស់!!ហ្នឹងហើយមីបងនោះទៅនៅឯចិត្តថៃងណោះ!!

កៈ នៅប៉ោយប៉ែត?

ខៈ នៅឯប៉ៃលិន។

ក :អើយឆ្ងាយណាស់លោកអើយ!!

ខៈ ហើយមេមួយបន្ទាប់នៅឯកោះដាច់!!មានស្វាមីនៅទីហ្នឹង!!

កៈ តែកោះដាច់វាមិនសូវនៅឆ្ងាយប៉ុន្មានទេតែគ្រាន់តែជិះមួយហាត់!!

ខៈ ហ្នឹងហើយឆ្លងដរទៅ!! កៈចាំ!!!កៈហើយអាមួយនេះនៅទួលក្រសាំង។

កៈ ចំចែកជើងគ្នា!!

ខៈ ចែកជើងគ្នា!!ឥឡូវអាមួយពៅនិងមានប្រពន្ធទៅនៅស្អី ទៅនៅស្អី ទៅនៅភូមិកក់
ភូមិស្អីណា!!

កៈ នៅតែកៃវឯណោះ!!

ខ :នៅតាកែវនឹងហើយឆ្ងាយ។

កៈ អាយដល់ពេលអញ្ជឹងទីបញ្ចប់អ្នកណាគេជាអ្នកនៅជាមួយអ្នកមីង?

ខៈ នៅនៅជាមួយចៅចៅហាក្នឹង!!

កៈ ហើយចៅចៅចុះឪពុកម្តាយនៅឯណា?

ខៈ ម្តាយឪពុកមាននៅប៉ៃលិនហ្នំ!!

កៈ ហើយយ៉ាងម៉េចបានទៅនៅ ពេលនៅកាត់ដំឡូងកាប់អីមែនទេអ្នកមីង?

ខៈ គេទៅធ្វើការ!!

កៈ ហ្ហ៎!!ហើយដល់ពេលបែបហ្នឹងគាត់ផ្តល់លុយមកចិញ្ចឹមពួកគាត់អញ្ចឹងទៅអ្នកមីង?

ខៈ ចាំ!!

កៈ ចំថៅរបស់អ្នកមីងមិនមែនតូចឯណា ធំៗអស់ហើយតើបងគេអាយុប៉ុន្មាន?

ខៈ នេះគឺជាបងគេហើយនេះ។

កៈ ដប់ឆ្នាំហើយមែនទេអាអូន?

ខៈ 10 ឆ្នាំជាងហើយ!!

ចៅៈ 13 ឆ្នាំហើយ។

កៈ អូយ នេះឯណា13 ឯណា!!

ខៈ មិនទាន់ទេ!!!

កៈ មិនទាន់ទេ។

ខ  ទើបតែ 11 e12។

កៈ ឥឡូវអ្នកមីងចូលដោយសង្គ្រាមតែម្តង នៅតែបន្តិចទៀតទេ!! អ្នកមីង របបលន់នល់សិន ខ្ញុំដឹងថាអ្នកមីទាន់សង្គ្រាមនៅពេលដែលទម្លាក់គ្រាប់បែក!!

ខៈ ជំនាន់ខ្មែរក្រហមមែនទេ?

កៈ មិនមែនទេជំនាន់ទម្លាក់គ្រាប់បែក!! មិនខ្មែរក្រហមអញ្ចោក អា 10 ឆ្នាំកំពុងតែពេញសង្គ្រាមនោះអាដប់ឆ្នាំចិន 70ដល់80ហ្ហ៎អ្នកមីង!!

ខៈ អាកា ប៉ាល់ហោះទំលាក់គ្រាប់ផ្លោងនិងមែនទេ??

កៈ ហ្នឹងហើយ អាឆ្នាំ 70រហូតដល់ 75រដ្ឋប្រហារទម្លាក់សម្តេចតើមែនទេ?

ខៈ ហ្នឹងហើយ។

កៈ ហើយអ្នកមិនរត់គេចខ្លួនយ៉ាងម៉េចដែរ?

ខៈ ចូល ក្នុងតែត្រង់សេ!!

កៈ នៅឯណាអ្នកមិញនៅពេលហ្នឹង?

ខ៖ នៅស្រុកនិង!!

ក៖ នៅអំពៅព្រៃនឹងមែនទេ?

ខ៖ ហ្នឹងហើយ!!

ក៖ ហៅយ៉ាងម៉េចមិនព្រមជម្លៀសទៅភ្នំពេញទៅ?

ខ៖ មានទៅឯណាអត់!!

ក៖ ដោយសារគេនិយាយថាអញ្ចាក
ម្ដាយរបស់ខ្ញុំបានប្រាប់ថានៅខេត្តហ្នឹងបតែត្រូវហើយសុទ្ធតែទម្លាក់ឡើងរប៉ាយ!!បើសិនជានៅទីក្រុងមិនអីទេ!!

ខ៖ ពេលកប៉ាល់ហោះមកៗចឹងទៅពេលនៅតូចតូចគ្មានដឹងថាកាប៉ាល់ហោះទម្លាក់ងាប់មិនងាប់អ្វីទេ!!!ចាស់ចាស់ដើរលេងជាមួយគ្នាអញ្ចឹងពេលមកអញ្ចឹងទៅចាស់ៗចេះតែអូសចូលទៅក្នុងត្រង់សេនិងណាស់!!! ក៖ចាំ!!ខ
ចេះតែចុះអូសចូលត្រង់សេណាក៏ដោយចេះតែចូលជាមួយគាត់ទៅដល់ពេលទម្លាក់ហើយអីហើយអញ្ចឹងទៅបានម្ដាយខ្ញុំដើររក!!

ក៖  ខ្លាចទម្លាក់ត្រូវៗចឹងទៅអ្នកមីងនមែនទេ?

ខ៖ ហ្នឹងហើយៗទៅដើររកអញ្ចឹងទៅឃើញអញ្ចឹងទៅបានយកមកផ្ទះវិញ
ដល់ពេលហើយគាត់ថាអញ្ចែកកុំពូកែដើរលេង
ពេកកូនណាស់តែមកងើងៗមកទម្លាក់ត្រូវងាប់មិនដឹងទៅរកឯណាទេ!!

ក៖ ហ្នឹងហើយអ្នកមីង1 រណ្ដៅមួយរណ្ដៅ ឮគេនិយាយ!!

ខ៖ ហ្នឹងហើយ1 រណ្ដៅមួយរណ្ដៅមិនមែនបន្តិចឯណា!!!

ក៖ ធំធំណាស់មែនទេអ្នកមីង?

ខ៖ ហ្នឹងហើយ!!

ក៖ ហើយចុះមិនមែនជំរៅទៅតែបន្តិចឯណា!!វាមិនសុទ្ធតែជ្រៅជ្រៅទាំងអស់!!

ខ៖ ហ្នឹងហើយ!!

ក៖ ហើយអ្នកមីងមានដែលលឺថាគេធ្លាក់ចំត្រូវអីដែរឬទេពេលហ្នឹង?

ខ៖ មានទេតើ!!

ក៖ ហើយវាយ៉ាងម៉េចទៅអ្នកវិញនៅពេលហ្នឹង?

ខ៖ បងប្អូនរបស់ខ្ញុំជីដូនមួយត្រូវ។

ក៖ ស្លាប់ឬមួយក៏ដាច់ដៃដាច់ជើង?

ខ៖ ស្លាប់ត្រូវតែម្តង។

ក៖ មួយគ្រួសារទេអ្នកមីងឬក៏តែមួយទេ?

ខ៖ តែមួយទេ។តែម្នាក់ទេ។

ក៖ ហើយវាយ៉ាងម៉េចបានជាគាត់ត្រូវគ្រាប់អញ្ចឹង?

ខ៖ គាត់រត់ចូលមិនទាន់នោះ!!រត់ចូលត្រង់សេមិនទាន់!!គាត់រវល់តែប្រវេប្រវារកកូននោះ!!

ក៖ ហ្អូយ!!

ខ៖ ដូចថាវាដើរលេងអញ្ចឹងទៅចុះបើកំពុងតែមកទាន់ហាន់ហើយនោះ!!

ក៖ ហ៊ឺហ៊ឺ!!!

ខ៖ រកមានទាន់ឯណា!!

ក៖ ភាគច្រើនអាយន្តហោះនិងអោយតែមកវាសុទ្ធតែឮពីនាយហើយមែនទេអ្នកមីង?

ខ៖ ហ្នឹងហើយ។

ក

:ខ្ញុំឆ្ងល់ថាហេតុអ្វីបានជាទំលាក់ចំប្រជាជនចុះអាពួកខូចខូចមិនព្រមទម្លាក់ទៅអត់ទេឈឺចាប់ណាស់អ្នកមីង!!

ខ៖ ចុះវាចេះតែនេះទៅ!!

ក៖ មិញពេលនិងមានដែល
នៅអំពៅព្រៃនិងមានដែលអត់មានផ្លាស់ប្តូរទៅឯណាទេមែនទេអ្នកមីងមែនទេ?

ខ៖ ចាំ!!

កៈ ហើយយ៉ាងម៉េចទៅអ្នកមីង
យ៉ាងម៉េចបានស្គាត់អាទំលាក់គ្រាប់ទៅវិញទៅដូចជាប៉ុន្មានថ្ងៃបានវាទំលាក់មកម្តងណាស់?

ខ៖ វាដូចជាមិនមែនមករាល់ថ្ងៃពីទេយូយូមក10
ថ្ងៃកន្លះខែមកម្តងកន្លះខែអីអញ្ចឹងទៅមកម្តងអញ្ចឹងទៅ!!

កៈ ហ្ហំយូរដែរ!!ហើយអ្នកមីងដូចជាលឺរឿងអ្វីស្តាប់លឺរឿងអ្វីខ្លះនៅក្នុងពេលជំនាន់និងខ្លះទៅ?

ខ៖ ដូចជាមិនសូវចាំដែរជំនាន់និងនៅក្មេងៗទៅនៅតូចតូចដែរ!!

កៈ ហ្នឹងហើយពេលហ្នឹងបើអ្នកមិន 18 ឆ្នាំនៅពេល!!

ខ៖ បើសំបកប៉ុលពតបានយើងដឹង ពេលហ្នឹងយើងនៅក្មេងៗយើងមិនសូវដឹង!!

កៈ ដោយសារពេលនឹងអ្នកមីងទើបតែ10 ឆ្នាំជាងទេ!!

ខ៖ ហ្នឹងហើយ!!!

កៈ អ្នកមីង10ឆ្នាំ កើតឆ្នាំ 1960 !!60 62 ឥវ៉ាន់និង!!!

ខ៖ ហ្នឹងហើយ!!

កៈ ដោយសារពេលហ្នឹង!!

ខ៖ ពេលហ្នឹងមិនដឹងនៅក្មេងក្មេង!!

កៈ គ្រាន់តែឃើញតែមួយឃើញគ្រាប់មករត់ព្រិច!!!

ខ៖ មកអញ្ចឹងទៅរត់ ចាស់ៗអូសចូល ទីណាទីហ្នឹងហើយ!!!

កៈ ចាំឥឡូវអ្នកមីងផ្លាយចូលមកបែបនេះវិញ
ដល់ពេលចប់លន់ណុលចូលប៉ុលពតវិញអ្នកមីងហោ?

ខ៖ ហ្នឹងហើយ។

កៈហើយអ្នកមានយ៉ាងម៉េចដែរដល់ពេលយ៉ាងម៉េចបានផ្លាយចូលអាសង្គ្រាមប៉ុលពតនិងអ្នកមិនមានអារម្មណ៍យ៉ាងម៉េចយ៉ាងម៉េចដែរ?

ខ៖ មានយ៉ាងម៉ិចពិបាកដែរហ្នឹង!!!

ក៖  អ្នកមីងយ៉ាងម៉េចដែរនៅពេលដែលលឺដំបូងថាជំនាន់ប៉ុលពត គេមានជម្លៀសអ្នកមីងទៅដល់ណាទេ?

ខ
:ខ្ញុំអត់មានជម្លៀសពីចូលនេះតែម្ដងចូលខាងនារីតែម្ដងចូលចូលកងនារីគេហៅចូលកងនារីតែម្ដង!!

ក៖ ចាំ ចុះពេលនឹងអ្នកមីងប្រហែលជាអាយុ 15 ឆ្នាំ?

ខ៖ ចូលពេលដំបូងគេមិនទាន់ទេទឹមតែឱ្យដើររែកណ្ដុររ៉ែអីអញ្ចឹងទៅណាស់ ដើរែកណ្ដុរមកវិញអញ្ចឹងទៅជាន់អង្ករជាន់អីហ្នឹ!!

ក៖ ចាំ!!

ខ៖ អាត្បាល់ជាន់គេនោះ  អាត្បាល់ជាន់យើងជាន់3 4 នាក់មួយត្បាល់ ពីរនាក់4 នាក់ជាន់ទៅ!!!

ក៖ ប៉ុន្តែអង្ករហ្នឹង យកទៅឱ្យឱ្យគេមែនទេអ្នកមីង?

ខ៖ អង្ករចូលទៅក្នុងហាងរបស់គេនោះ!!!

ក៖ ហើយចុះមានអ្នកណាគេមើលពេលអ្នកមីង?មើលយាមកុំឲ្យយើងយកទេ?

ខ៖ មានទេតើ!!ហ៊ឺ!!មានតើមានមេគេ!!

ក៖ សុទ្ធតែមានទៀត!!

ខ៖ យើងដូចមុនបានទេលួចមិនបាន!!

ក៖ អញ្ចឹងសុទ្ធតែក្រុម នីមួយនីមួយចែកជើងគ្នាសុទ្ធតែមានមេ?

ខ៖ សុទ្ធតែមានមេទាំងអស់។

ក៖ អ្នកណា យកតែបន្តិច!!

ខ៖ ហ៊ឺ យកតែបន្តិចនឹងស្លាប់ងាប់របស់គេហើយ!!

ក៖ តែអត់មានអ្នកណាគឺចិត្តល្អទេអ្នកមីងនៅពេលនិង?

ខ៖ មានដែលអ្នកចិត្តល្អចិត្តហើយអ្នកចិត្តអាក្រក់មានដែរ
អ្នកចិត្តល្អៗចឹងទៅដូចជាឃើញនេះអញ្ចឹងទៅខ្លះទៅគេលួចអោយខ្លះចឹងទៅណាស់
លួចឲ្យលួចអីអញ្ចឹងទៅណាស់។

ក៖ តែក៏នៅមានអ្នកចិត្តបុណ្យដែរមែនទេអ្នកមីង?

ខ៖ នឹងហើយក៏នៅតែមានអ្នកចិត្តល្អវាមិនអត់មានទេ!!

ក៖ ចាំ!!សុទ្ធតែអញ្ចឹងតែម្តង!!

ខ៖
បើខ្ញុំនៅទីនេះនៅម្តុំទីនេះពេលយប់ឡើងអញ្ចឹងមើលតែមាន់រងាវម្ចាស់ផ្ទះគាត់ដើរដាស់ហើយ
ណាស់គាត់ដើរហើយធ្វើការអញ្ចឹងយប់ អើរ
ទៅធ្វើអញ្ចឹងមិនគេនេះបាយ!!គេដួសបាយឲ្យហូបនោះដោយពេលនោះយើងនាំគ្នាផ្អឹបចានដា
ក់ចូលក្នុងថង់ដាក់បាយមួយចាននិង ឡើងណែនទៅដាក់ចាន
ផ្តុំគ្នាដាក់ចូលក្នុងស្បោងស្តាយទៅ!! ក៖ចាំ!!ខ៖ហ្នឹង
ហើយដល់ពេលយប់ឡើងទៅមើលតែមាន់រងាវអញ្ជើញម្ចាស់ផ្ទះគាត់ដាស់ហើយណាស់អោ
យហូប ចង់យើងកាលពីពេលហ្នឹងអត់មានអំបិល មានតែអីនឹងចេះតែហូបទៅ។

ក៖ ហ្នឹងហើយធ្វើយ៉ាងម៉េចឲ្យតែពេញពេញពោះទៅកុំអោយកូរពោះ!!

ខ៖ នឹងហើយធ្វើយ៉ាងម៉េចឲ្យតែឆ្អែតឆ្អែតទៅ
ហ្នឹងហើយគាត់ដើរដាក់ឲ្យក្រោកនាំគ្នាស៊ីហើយអញ្ចឹងទៅអត់មាន
នាំគ្នាអុជចង្កៀងទេនាំគ្នាស៊ីពេលងងឹតទៅស្វាត់ស្វាត់ទៅ!!!

ក៖ ហើយស្លម្បីតែទំពាក់មិនអីដែរមានទេអ្នកមីង?

ខ៖ ហ្នឹងហើយ។លាងចានលាងអីហើយអញ្ចឹងផ្កាប់ចូលអាក្នុងស្បោង!!

ក៖ ស្តាយនិងអញ្ចឹងទៅ??

ខ៖ ស្តាយនិងវិញទៅគ្រាន់តែហូបហើយមួយសន្ទុះអញ្ចឹងទៅទៀត គេដើរហៅហើយ
ទៅហើយហាំ!!នាំគ្នាដើរប្រផ្លាកប្រផ្លុង នៅងងុយគេងនៅអីហ្នឹងណាស់!!

ក៖ ហ្នឹងនិងវាប្រកាច់យកយកស្អីគេទេវាទេអ្នកមីង??ដូចថា
របៀបអោយធ្វើការឲ្យធ្វើការតាំងពីព្រលឹម ព្រលឹមអុល!!

ខ៖ ហ្នឹងហើយ!!

ក៖ ឲ្យធ្វើដល់យប់ណានី។

ខ៖ ហ្នឹងហើយជូនកាលឲ្យធ្វើឲ្យម៉ោង 6 ម៉ោង 7ដោយយប់ណានៃហើយបានឲ្យឡើងមកពីទឹកវិញហើយ!!

ក៖ យប់ហ្នឹង?

ខ៖ ហ្នឹងហើយម៉ោង 6 ម៉ោង7 យប់យើងនឹង!!

ក៖ ហើយចុះបើសិនជានៅក្នុងទឹកអ៊ីចឹងមានភ្លើងមានអីអោយទេឱ្យទេអ្នកមីង?

ខ៖ មានភ្លើងស្អីតើម៉ោង 6 ឡើងហើយឡើងមកអញ្ចឹងទៅយើងហូបបាយហូបអីអញ្ចឹងទៅយើងទម្រាំតែហូបបាយហូបអ្វីហើយទម្រាំតែដើរមកដល់ផ្ទះម៉ោង 7!!!

ក៖ ចាំ!!ហើយចុះអ្នកមីងពេលនៅធ្វើការនៅក្នុងទឹកមានចាប់បានអ្វីខ្លះហូបទេគ្រប់គ្រាន់ទេអ្នកមីង?

ខ៖ គ្មានស្អីទេមានតែអាពស់អាពស់ឈើពស់ព្រលិតយើងនឹង!!

ក៖ ខ្យងខ្ចៅអីវ៉ាន់មានហូបទេ?

ខ៖ ខ្យងអោយតែបានមកដុតហើយ!!

ក៖ ហ្វ៎ ក្នុងទឹកណាស់នៅក្នុងទឹកជំនន់នឹងខ្ញុំគិតថាស្អីក៏មិនខ្វះដែលអ្នកមិនមែនទេ?

ខ៖ ហ្នឹងហើយ!!!ប៉ុន្តែគ្រាន់តែថាទឹកវាជ្រៅ ទឹកវាជ្រៅណាស់យើងបានហើយបានដែរបានតែខ្យង បានតែ ពស់ឈើពស់ព្រលិតអ្វីទាំងអស់និង។

ក៖ ត្រីដែលចាប់បានទេអ្នកមីងត្រី ទេ?

ខ៖ មិនដែលទេវាទឹកជ្រៅជ្រៅពេកសុទ្ធតែទឹកត្រឹមត្រឹមនេះនោះ។

ក៖ នៅក្នុងនឹងធ្វើស្អីគេខ្ញុំឆ្ងល់??

ខ៖ កាត់ស្មៅ កាត់ស្មៅទាំងផ្ទាំងទាំងផ្ទះនាំគ្នាអូសអូសមកចោលនៅខាងលើងណោះ

ក៖ ហើយដើម្បីអោយទឹកមិនស្អាត?

ខ៖ ហ្នឹងហើយគេចេះតែប្រើទៅ!!!ហ្នឹងហើយ!!

ក៖ វាចេះតែប្រើពួកអាប្រម៉ាត់ប្រម៉ង់។

ខ៖ យើងធ្វើយ៉ាងម៉េចកុំឲ្យតែមានពេលទំនេរ!!!

ក៖ ខ្ញុំឆ្ងល់ធ្វើយ៉ាងម៉េចពូកែរកនឹកដល់ក៏ហើយ!!

ខ៖ ហ្នឹងហើយ។ស្មៅវិញកាប់មួយនេះ 4
ជ្រុងៗចឹងទៅនាំគ្នាទាញទាំងបីបួននាក់អញ្ជឹងទៅយកមកដាក់នៅខាងលើមក។ក៖ចា!!ខ៖យ
កមកដាក់ខាងលើនៅលើទំនប់ខាងនេះមក ។ក៖ចាំ!!!ខ៖ និងនិងហើយអញ្ជឹងទៅ
ទៅចឹងទៅហើយនាំគ្នាទៅទៀតទៅចឹងទៅហើយនាំគ្នាទៅទៀត។

ក៖ ទឹកប៉ុណ្ណាអ្នកមីងធំដែរឬទេ?

ខ៖ ហ៊ឹ អានេះយើងពាសវាលពាសកាលបឹងប៉ុណ្ណាប៉ុណ្ណឹនិង!!

ក៖ អាមួយហ្នឹងវាយ៉ាងម៉េចទេវាខ្ញុំឆ្ងល់ដល់ហើយ!!

ខ៖ ហ្នឹងហើយ!!

ក៖ វាធ្វើយ៉ាងម៉េចថាកុំអោយមនុស្សនៅទំនេរ ។

ខ៖ ធ្វើយ៉ាងម៉េចកុំអោយតែទំនេរតែម្តងនឹងណាស់!!

ក៖ ហើយមានអ្នកមើលទៀតទេ?

ខ៖ មាន!!!

ក៖ វាមើលអីក៏មើល យ៉ាងនេះមាឌប្តូរផ្លាស់គ្នាមើលឬក៏តែម្នាក់?

ខ៖ វាសុទ្ធតែឈើបញ្ជា យើងពីលើទៅនោះ។

ក៖ កាន់កាំភ្លើងមួយទៅអ្នកមិនមែនទេអ្នកមីង?

ខ៖ កាំភ្លើងគេហើយនិងអាមេធំគេនឹងអាវខ្មៅក្រមាក្រហាមមួកគេនឹងនោះ។

កៈ គេឡូយគេខ្លាំងណាស់។

ខៈ ហ្នឹងហើយគេដើរបញ្ច្រាឯង!!

កៈ ខ្ញុំឆ្ងល់ពួកនិងសម្បូរណាស់វាមកពីណាខ្លះទៅអ្នកមីង?

ខៈ ហ៊ឺមិនដឹងមកពីណាពីណាទេ។

កៈ ដោយសាសាខ្មែរគ្នាឯងនិងខ្ញុំបានសួរជនជាតិគេ!!

ខៈ សុទ្ធតែជនជាតិឯងហ្នឹង មានអាខ្លះកាចមានអាខ្លះស្លូត។

កៈ អ្នកមានខ្ញុំសួរជនជាតិគេខ្ញុំសួរថា
តើអ្នកឯងគិតថានៅប្រទេសខ្មែរហើយនិងនៅប្រទេសសេរីសព្វថ្ងៃតើមួយណាអាក្រក់ជាងដោយសារសព្វថ្ងៃនៅរាល់ថ្ងៃហ្នឹងអ្នកមីង!!

ខៈ ហ្នឹងហើយ។

កៈ៖ នៅប្រទេសសេរីគេបាញ់គ្នាឡើង 7
8ឆ្នាំអត់ទាន់បាត់ទេអ្នកមីងឥឡូវអ្នកមីងណាស់!!ខ្មែរយើងតែបីឆ្នាំ4ឆ្នាំទេ!!ហើយដល់ពេលបែបហ្នឹងទៅគាត់ថានៅប្រទេសខ្មែរយើងសាហាវជាងដឹងទេអ្នកមីងសាហាវនៅត្រង់ណាទេសម្លាប់ជនជាតិខ្មែរឯងគេថាប្រល័យពូជសាសន៍គ្នាឯងអញ្ចឹងណាស់។

ខៈ នេះអាងតែខុសបន្តិចអាចនឹងយកបាញ់ចោល។

កៈ ហ្នឹងហើយហើយអ្នកមីងអ្នកមានធ្លាប់ឃើញសាកសព
មនុស្សឥវ៉ាន់គេយកទៅសម្លាប់ចោលទេអ្នកមីង?

ខៈ អត់ដែលឃើញទេ!!!ពេលងាប់ទៅគេយកទៅតែម៉ុស្នីគេហើយតែកោះគយើងនេះ!!!

កៈ អ្នកមិនព្មមួយហ្នឹងដែរ?

ខៈ ហ្នឹងហើយ!!!

កៈ នៅទីហ្នឹងគេថាល្បីខ្លាំងណាស់ឱ្យតែមកភាគច្រើនគឺ!!

ខ៖ ហើយកោះគរហើយនិងខ្ញុំនៅគ្រាន់តែឆ្លងហ្នឹង!!ក៖ហ្ន៎!!ខ
ការយល់ទៅគ្រាន់តែឆ្លងកោះគរពួកខ្ញុំនៅត្រើយខាងណោះយកទៅសម្លាប់នៅត្រើយហាង
នោះនឹង។

ក៖ ហ៊ឺ!!ដែលឮសំលេងអ្វីទេអ្នកមីង?

ខ៖ អត់ដែលទេ!!

ក៖ ដោយសារខ្ញុំថ្ងៃមុន!!

ខ៖ ពេលនៅឆ្ងាយឆ្ងាយនឹងហើយ!!

ក៖ ហ្ន៎ ដោយសារថ្ងៃមុនខ្ញុំបានសម្ភាសលោកពូម្នាក់នៅជិតកោះគរ
អាទំនប់ទូលក្រសាំងអីវ៉ាន់នឹងនោះអ្នកមីង

ចា៎ហើយ ផ្ទះគាត់ឥឡូវនៅចិត្តកោះគរហ្នឹង!!

ខ៖ ហ្នឹងហើយ!!

ក៖ ហើយដល់ពេលឥឡូវគេធ្វើភូមិ!!

ខ៖ ឥឡូវបែភ្លេងមានខ្មោចហើយវាមិនមែនអស់ហើយសុទ្ធតែផ្ទះអស់ហើយ។

ក៖ ចា៎ហ្នឹងហើយ!!

ខ៖ មិនមែនដូចនៅស្រុករចំបក់អាប៉ុលពតនិងទេ!!!

ក៖ គេថាបន្ទាប់ពីគុកទូលស្លែងនៅទីនោះហើយអ្នកមីង គេហៅស្អីអា ករ5 ហ្នឹងហើយ07 08
ហ្ន៎អ្នកមីង!!

ខ៖ ក 5 ក 6អីគេនោះ!!

ក៖ ហ្នឹងហើយ!!នឹងហើយអាហ្នឹងហើយមន្ទីរ 08
បន្ទាប់ពីគុកទូលស្លែងមកអ្នកមីងណាស់!!ខ្ញុំលឺនិយាយបែបហ្នឹងហើយចឹងពេលអ្នកមីងនៅទីនិ
ងនូវអំពៅព្រៃតើយ៉ាងម៉េចបានមកនៅស្អាងព្រែកតូចនេះវិញ?

ខ៖ ចុះពេលចំបក់អាពតគេមិនអោយយើងទៅនៅទីហ្នឹង!!

ក៖ ហ្ន៎!!!គឺគេគារពីទីនោះមកពីនិងវិញបានទេ?

ខ៖ គេគៀរអីទៀតហើយគេឲ្យទៅនៅតាមកង!!

ក៖ ហ្នឹយល់ហើយ!!

ខ៖ ទៅនៅតាមសហករណ៍តាមក្រុមក្រុមគេនោះ តាមនេះតាមផ្ទះ
អញ្ចឹងទៅណាស់!!មួយផ្ទះដាក់ 4 5 នាក់អញ្ចឹងទៅមួយផ្ទះដាក់ 4
5អ្នកអញ្ចឹងទៅ!!តាំងដេកទៅណាស់ដល់ពេលភ្ញាក់ភ្លឺឡើងៗចឹងទៅតម្រង់ជួរតម្រៀបជួរគ្នា 2
ឬក៏ 3 ជួរអញ្ចឹងទៅមកធ្វើការ!!

ក៖ តើអ្នកមីងពេលការហូបចុកយ៉ាងម៉េចដែរបានដែរតើមែនទេ?

ខ៖ ការហូបចុកវេទនាណាស់ដែលនឹង!!

ក៖ ចុះអំបាញ់មិញបានអីហូបដែរតែមិញប្រាប់អម្បាញ់មិញ?

ខ៖ ហ្នឹងសុទ្ធតែលួចនោះ។

ក៖ ហ្នឹ តែដល់ពេលអាមែនទែនអាម៉េចទៅអ្នកមីង?

ខ៖ ជួនកាលបាយយើងលាយអាដំឡូងហ្នឹ!!

ក៖ ថ្ងៃណាមួយខ្ញុំចង់ដាំបាយលាយដំឡូងដែរតើមានរសជាតិយ៉ាងម៉េចទៅខ្ញុំនេះហ៎??

ខ៖ លាយពោតលាយដំឡូងអង្ករតែ 1 គ្រាប់ 1 គ្រាប់និង។

ក៖ ឲ្យមានរសជាតិលែមៗទេអ្នកមីង?

ខ៖ គ្មានទេគណៈអំបិលលាយអោយយើងទេ។

ក៖ តែអ្នកមីងពួកអ្នកធ្វើការមានមានអីស៊ីគ្រប់គ្រាន់ទាំងអស់តែម្តងមែនទេ?

ខ៖ a កន្លែងណាគេគ្រប់គ្រាន់គ្រប់គ្រាន់ទៅសំបូរសំបូរទៅកន្លែងណារហោមរហាម
រហោមរហាម។

ក៖ រួចអ្នកមីងដែលធ្លាប់អាបបរមួយខ្ទះត្នោតអង្ករ2 3 កំប៉ុងនិងដែលទេ?

ខ៖ អាទឹករាវៗហ្នឹងហេ?

ក៖ ហ្នឹងហើយអ្នកមិនធ្លាប់ដែរឬទេ?

ខ៖ អត់ដែលទេ!!!

ក៖ ហេងហើយ អញ្ចឹង!!

ខ៖ ហ្នឹងហើយខ្ញុំមិនដែលធ្លាប់ទេ!!ខ្ញុំហូបតែបាយបើបាយបាយលាយដំឡូង។

ក៖ ចាំ ពេលនិងម៉ែហើយនិងប៉ានៅឯណាវិញ?

ខ៖ គាត់នៅស្រុកឯងហ្នឹង។

ក៖ ហើយអ្នកមានគេបញ្ជូនទៅទីនោះទៅ។

ខ៖ ហ្នឹងហើយខ្ញុំគេបញ្ជូនទៅព្រៃកតូចនិង។

ក៖ ដែលឮដំណឹងអ្វីពីឪពុកម្ដាយទេ?

ខ៖ អត់ទេ ឪពុកម្ដាយខ្ញុំនៅចំបក់អាពតគាត់អត់អីដែរ។

ក៖ គាត់ស្រណុកដែរមែនទេ?

ខ៖
ហ្នឹងហើយ។អត់ស្រួលដែរទេតើមើលកង់កញ្ចាស់មួយជូនកាលអាបាយអង្ករអង្ករបាយយើងនឹងតាមទៅគាត់ហាល!!ហាល ហើយគាត់មិនលីងពោតធ្វើនេះនោះដាក់ស្ករ។

ក៖ ចាំ ហើយគេមិនបានដឹងដែរមែនទេអ្នកមីង?

ខ៖ ហ្នឹងហើយ អត់ទេគាត់ធ្វើពេលយប់ៗចឹងទៅជូនកាលធាក់កង់យកទៅឲ្យហើយ
ដាក់លាក់!!

ក៖  តែឆ្ងាយណាស់ណាស់មែនទេអ្នកមីង?ពីអំពៅព្រៃទៅស្អាងណាស់!!

ខ៖ ចុះយើង!!

ក៖ ចេះតែទៅហើយ។

ខ៖ យើងគាត់នេះដែរ គាត់ខាងដាំទឹកតែទឹកអីអញ្ចឹងទៅណាស់។

ក៖ អោយពួកមេមេ!!!

ខ៖
ហ្នឹងហើយអោយមេមេគេអញ្ចឹងទៅគាត់ដាំទឹកតែក៏ថៃចំការថៃគេចំការក្រូចចំការអីនឹងណាស់!
!

ក៖ ហ្នូ!!!អញ្ចឹងគាត់ហោងដៃរគាត់បានហូបអ្វីស្រួលបួលដែរ!!

ខ៖ ហ្នឹងហើយ!!

ក៖ តែហូបកុំអោយគេឃើញមែនទេអ្នកមីង?

ខ៖ ហ្នឹង ហើយគាត់មិនសូវយ៉ាបយ៉ើនប៉ុន្មានទេឪពុកខ្ញុំ!!!

ក៖ អញ្ចឹងបានមួយៗ!! ហើយបងប្អូនក៏បែកទៅតាមកងផ្សេងៗដែរមែនទេ?

ខ៖ ហ្នឹងហើយ បែកទៅកងផ្សេងៗទាំងអស់។

ក៖
ចុះបងស្រីអ្នកមីងអាយុល្បាក់ៗអ្នកមីងដែរយ៉ាងម៉េចគាត់មិនទៅជាមួយនៅជាមួយអ្នកមីងទេ
មែនទេ?

ខ៖ អត់ទេបែកគ្នា។

ក៖ បែកគ្នាយ៉ាងម៉េច?

ខ៖ គេដាក់មួយដំណាក់មួយដំណាក់ណាស់ថាបងខ្ញុំចឹងទៅគេខាងធំៗៗៗទៅ
ពួកខ្ញុំខាងតូចតូចអញ្ចឹងទៅអត់ដាក់អោយ ជិតគ្នាទេ!!

ក៖
អញ្ចឹងអ្នកមីងការងាររបស់អ្នកមីងពេលក្នុងជំនាន់ប៉ុលពតទៅកាត់ទឹកកាត់ស្មៅនៅក្នុងទឹក!!

ខ៖ ហ្នឹងហើយ!!កាត់ស្មៅនៅក្នុងទឹក!!

ក៖ រែក ដីនៅទំនប់ទួលក្រសាំងនេះ!!

ខ៖ ហ្នឹងហើយ!!!

ក៖ ហើយមានអ្វីទៀតទេអ្នកមីង?

ខ៖ មានតែប៉ុណ្ណឹងមានតែរែកដីកាត់ស្មៅ!!

កៈ 3ឆ្នាំ 8 ខែ 20 ថ្ងៃធ្វើបែបហ្នឹងរហូត?

ខៈ ជូនកាលទៅថៃគេអោយវាធ្វើត្រីនៅស្អី!!

កៈ កោះធំមែនទេ?

ខៈ មិនមែននៅកោះធំទេ!!

កៈ ត្រើយស្លាមែនទេ!!

ខៈ ស្អីប្រសាទតាយូរ។

កៈ អត់ស្គាល់ផង។

ខៈ ទៅប្រាសាទតាយូយើងឯណោះ។

កៈ ឆ្ងាយណាស់មែនទេអ្នកមីង?

ខៈៈឆ្ងាយណាស់!!!!នាំគ្នាដើរអត់មានអ្វីជាងណាសុទ្ធតែដើរហ្នឹងទៅវាឃើញអាត្រីច្រើននិងមីអូនអើយអាត្រីយើងគេហៅត្រីកន្ធរ យើងនឹង!!!

កៈ ចាំចាំស្គាល់ហើយ!!

ខៈ យើងនឹងមិនពង!!

កៈ នឹងហើយ។

ខៈ
គេដាក់មកទាំងទូកៗចាក់មកឲ្យយើងធ្វើអញ្ចឹងទៅណាស់ដល់ពេលហើយយើងធ្វើហើយយើងយកមកពងនិងនាំគ្នាយកមកប្រលាក់អាំងបង្កាត់ភ្លើងនាំស៊ីទៅវាគ្នាយកមកប្រលាក់អាំងបង្កាត់ភ្លើងនាំស៊ីទៅវាពគអាចមន៍គ្រប់គ្នា!!

កៈ យ៉ាងម៉េចបែបហ្នឹង?

ខៈ អាត្រី កន្ធរ ហូបទៅវាកអាចម៍តើ!!!

កៈ ហ្ហ៎!! វាឃើញពងវាល្អពេកមែនទេ?

ខៈ ពងវាសុទ្ធតែពងតែម្តងទៅណាស់ពងឡើងឲ្យទ្រលុកទ្រលន់។

កៈ ពេលយកទៅអាំងនិងពួកវាអត់ថាអីគេដែរអ្នកមីងហោ?

ខៈ ពងទាអត់អីដែរនិយាយយើងវាមិនអត់អីទេយើងសុទ្ធតែលាក់!!

កៈ កុំបើកចំហខ្លាំងពេក!!

ខៈ ហ្នឹងហើយ!!!

កៈ អ្នកមីងណោះ!!

ខៈ
បើកចំហឯណាសុទ្ធតែលាក់ហ្នឹង!!!ហើយដល់ពេលហើយទៅសុំអំបិលអ្នកម្ចាស់ផ្ទះនិងវាគ្មានប៊ីចេងគ្មានស្អីទេមានតែអំបិលប្រឡាក់ប្រឡាក់បន្តិចបន្តិចទៅនឹងហើយដាក់ៗចឹងទៅដល់ពេលហើយនាំគ្នាស្រវាស៊ីគ្រប់គ្នានិយាយថាពីរាកអាចម៍!!

កៈ មួយៗឡើងអស់កម្លាំងអស់រលីងទៅ!ដល់ពេល!!

ខៈ ដល់ពេលហើយទៅចាស់ៗនៅស្រុកនិងគេថាអញ្ចេក ព្រលឹមឡើងមីអូន ហ្អែង
នាំគ្នាស៊ីត្រីកន្ធរហ្នឹងពងត្រីកន្ធរនិងព្រលឹមឡើងយ៉ាងម៉េចដែរ??ហ៊ូ ស៊ីអា
ពងត្រីនឹងមិននាំគ្នារាកអាចម៍!!
គាត់ថាពងត្រីកន្ធរនិងរាគអាចម៍តើកុំស៊ីច្រើនពេកបើនាំគ្នាស៊ីបានតែបន្តិចបន្តិចអត់អីទេស៊ីច្រើន រាកអាចម៍,!!

កៈចា៎!!អរគុណមែនទែនអ្នកមីងសម្រាប់ការសម្ភាសអំពីជីវិតរបស់អ្នកមិនដែលទាក់ទងទៅនឹងជំនាន់ប៉ុលពតអញ្ជើញទៅអ្នកមីងណាស់!!

ខៈ ជំនាន់ប៉ុលពតគឺយ៉ាប់ដែលនឹង!!

កៈ តែហោងហើយមែនទេអ្នកមីងមែនទេ!!

ខៈ ហ្នឹងហើយ!!!វាអត់បានគេសម្លាប់!!

កៈ ហោងហើយអ្នកមីងអើយ!!

ខៈ ហ្នឹង!!!

កៈ អរណាស់មែនទេអ្នកមីងថាពេលបែកពីជំនាន់ប៉ុលពតមកធូរខ្លាំងទេអ្នកមីង?

ខ៖
ពេលបែកពេលបែកគេមិនមានអាគេអាយើងតាមផ្លូវទួលក្រសាំងមិនគេអោយមកអញ្ចេះ!!!ក៖ ចាំ!!ខ ៖មានគេនៅឈរនៅទីហ្នឹងនោះពុកខ្ញុំណា2 3
នាក់អត់មានទៅតាមនឹងគេទៅតែតាមប្រលោះក្លៀកគេ តែស្រវ៉ាអ្វីមកដល់ផ្ទះ
ឯកន្ទេលមុងស្អីក៏មិនយល់ដែរខោអាវក៏មិនយកដែរស្លៀកតែមួយកំប្លេ។

ក:ចាំ!! ដោយសារពុទ្ធនិយាយថាទ័ពវៀតណាមចូលមកមែនទេអ្នកមីង?

ខ៖ ហ្នឹងហើយ!!

ក៖ រត់ចែកជើងគ្នាតែម្តងមែនទេអ្នកមីង?

ខ៖
ហ្នឹងហើយរត់ចែកជើងគ្នាតែម្តងអីក៏មិនយកមកដែរ!!វ៉ាលីខោអាវអ្វីក៏មិនយល់ដែររត់យកតែព្រះអាយុសរួចតែខ្លួន។

ក៖ និងហើយទៅខ្វល់អ្វីអាអញ្ជឹងអញ្ជឹង!!

ខ៖ ខ្វល់អ្វីខោអាវអោយតែបានដល់ផ្ទះ
មើលដើរគួរសំដែរនិងទាំងពីរនេះទេដល់ម៉ោងទំរាំតែដែរដល់ផ្ទះ។

ក៖ ដើរវកាត់ព្រៃកាត់ផ្សេងអញ្ជឹងទៅអ្នកមានមែនទេ?

ខ៖ ដើរកាត់!!

ក៖ អញ្ជឹងអ្នកមិនដើរកាត់បើសិនជាដើរគៃលវាងឆ្ងាយណាស់មែនទេ?

ខ៖ ហ្នឹងហើយ។

ក៖
ភ័យណាស់អ្នកមីងអើយដែលដើរចូលមកបាញ់គ្នាតូងតាំងពេញទីនិងតែម្តងអ្នកមីងហេ៎??ចុះអាមេអាពតនោះរត់ទៅឯណាវិញទេអ្នកមីង ?មេក្រុមរបស់អ្នកមីងនោះណាស់?

ខ៖ វារត់ចូលព្រៃបាត់អស់ហើយទើបទៅអាខ្លះមុខផ្ទះទៅ។

ក៖ មានគេចាប់បានដែរអ្នកមីង?

ខ៖ បានទេតើអាណាចិត្តអាក្រក់។

កៈ ចាំសម្លាប់វិញទេអ្នកមីង?

ខៈ គេទៀតបាញ់ចោល។

កៈ សម ពួកវាទាំងអស់និងអាក្រក់ណាស់អ្នកមីង!

ខៈ នៅក្នុងភូមិញុមមានមួយដែលគេវៃចោលទេតើ ចិត្តអាក្រក់ពេក!!

កៈ សមមុខ!!

ខៈ ហ្នឹងហើយមិនមែនអ្នកឆ្ងាយឯណាទេសុទ្ធតែបងប្អូនជីទូតមួយអីដែរហ្នឹង!!!

កៈ ចេះតែលើកបន្ទុបលើកបន្ទុប!!

ខ ជីតដែលនឹងណាស់!!នឹងហើយប៉ុន្តែវាសាហាវតែម្តង!!

កៈ អត់ទេវាពូកែបណ្តុះគំនិតណាអ្នកមានមែនទេ?

ខៈ ហ្នឹងហើយ។

កៈ វាសាហាវណាស់
។អញ្ចឹងអ្នកមីងពេលបែកមកបងប្អូនបានជួបជុំគ្នាវិញហើយមែនទេអ្នកមីងណោះ?

ខៈ ហ្នឹងហើយបានជួបជុំគ្នាវិញ។

កៈ ចាំ ហៅបងស្រីអ្នកមិនឮប្រាប់ថាពេលមុនថារៀបនៅក្នុងអាពតនឹងដែរទៅ?

ខៈ ចាំ!!!

កៈ
ហើយដល់ពេលហើយអ្នកមិនរៀបការជាមួយនឹងលោកពូតែម្តងហើយរកស៊ីឥវ៉ាន់អញ្ចឹងទៅមែនទេ?

ខៈ ហ្នឹងហើយ!!

កៈ  បន្ទាប់ពេលហ្នឹងមកគ្រប់ពីអ្វីដែលអ្នកមីង?

ខៈ ធ្វើស្រូវដែរ។

កៈ ធ្វើស្រូវនូវអំពៅព្រៃនិងទៅអ្នកមិនមែនទេ?

ខ៖ នឹងហើយធ្វើនូវអំពើព្រៃស្រូវប្រាំងស្រូវស្រែលើ!!អញ្ជឹងទៅ!!

ក៖ អ្នកមីងហេតុអ្វីមកនៅតាអាត់វិញ?

ខ៖ អាហ្នឹងវាចេះតែបែកបែកគ្នាទៅ។បើពួកយើងនៅក្នុងភូមិទៅវាដីតែបន្តិចពេក។

ក៖ ហើយម្ដាយមិនចែកផ្ទះនិងអោយទេកូនពៅ?

ខ៖ អត់!!

ក៖
ដោយសាររខ្ញុំកូនពៅម្ដាយរបស់ខ្ញុំចែកផ្ទះអោយខ្ញុំណាស់!!!អ្នកមីងប្រហែលជាសល់ពីសំនួរទៀត ជីវិតរបស់អ្នកមីងវេទនាបំផុតនៅពេលណា?
ដែលអ្នកមីងគិតថាវេទនាចងចាំទុកក្នុងចិត្តតែម្ដងបំភ្លេចមិនបាននឹងណាស់?

ខ៖ ហ្នឹងហើយ!!!

ក៖ ពេលណា វិញអ្នកមីងអត់។

ខ៖ សូវវេទនាដែរខ្ញុំ។

ក៖ យ៉ាងម៉េចដែរអ្នកមីង!

ខ៖ វាមិនវេទនាប៉ុន្មានទេមានកូនមិនមានក្រក៏មិនក្រមានត្រឹមតែមធ្យម។

ក៖ មធ្យម!!

ខ៖ គ្រាន់តែយើងមានរកមិនសល់!!

ក៖ ហ្ន៎ ចាយច្រើនពេកមានទេអ្នកមីង?

ខ៖ អត់!!!អត់បានចាយ
ដូចថាយើងរកបានតែបន្តិចអញ្ជឹងទៅយើងចាយសល់បានទុកឲ្យកូនឈឺថៅឈឺ!!
អញ្ជឹងទៅអញ្ជឹងណាស់!វាមិនសូវ!!

ក៖ សល់លុយច្រើន??

ខ៖ វាមិនសូវបានលុយច្រើន។

ក៖ ចុះចំណែកពេលដែលសប្បាយវិញ?

ខ៖ ទឹម តែមកឥឡូវទេកូនទាំងអស់ពួកគេធ្វើការ
ពេលមុនកូនមិនទាន់បានធ្វើការអ្វីពិបាកពិបាកដែរនឹងណាស់ហ្នឹងហើយវាចាប់យើងដែរគ្រាន់តែរកមកបានតែមួយមុខម្ហូបអញ្ចឹងទៅណាស់មកឥឡូវកូនគេធ្វើការទៅគេមានប្ដីគេមានអ្វីនេះទៅគឺជួយអ្វីខ្លះអញ្ចឹងទៅវាធូរធារបន្តិចអញ្ចឹងដែរទៅ!!

ក៖ ដូចឆជួយគ្នាមួយនាក់មួយដងៗចឹងអ្នកមីង!!

ខ៖ ហ្នឹងហើយ។

ក៖ ដល់ពេលមុនអ្នកមានអ្នកចិញ្ចឹមគាត់ដល់ពេលធំឡើងធ្វើការចិញ្ចឹមអ្នកមីងវិញ?

ខ៖ នឹងហើយចិញ្ចឹមម្ដងវិញទៅ!!

ក៖ ចាំ
អញ្ចឹងអ្នកមានមួយនេះគឺជាសំនួរមួយចុងក្រោយមានអ្វីមានពាក្យអ្វីចង់ប្រើប្រាស់តែកាន់កូនចៅជំនាន់ក្រោយក៏ដូចជាប្រជាជនខ្មែរយើងដែលគាត់បានស្ដាប់ឮសំឡេងរបស់អ្នកមីងអ្នកមីងចុងប្រៀនប្រដៅគាត់ឲ្យដើរលើផ្លូវយ៉ាងម៉េចដែរ?

ខ៖ កុំឲ្យដើរលើផ្លូវជំនិងណាស់។ក ៖ចាំ!!
ខ៖កុំឲ្យដើរទៅជាតាផ្លូវអាក្រក់យើងធ្វើយ៉ាងម៉េចធ្វើអោយតែល្អទៅអោយគេអាណិតគេចូលចិត្តអញ្ចឹងទៅណាស់ទេធ្វើអំពើអាក្រក់
ដើរឈ្លោះគេ!!!កូនរបស់ខ្ញុំស្រួលណាស់មីអូនអត់ចេះរឿងរ៉ាវឈ្លោះគេធ្វើអីរករឿងគេអីវាស្រួល!!

ក៖ តែពួកគាត់ដូចជាអត់មានធ្វើអ្វីដែលខុសឆ្គងដែរទេអ្នកមីង?

ខ៖ អត់មានទេ!!

ក៖ ប្រាសាទអ្នកមានខ្ញុំលឺអំស្រីមួយនោះ គាត់និយាយថា!!

ខ៖ កូនរបស់ខ្ញុំស្រួលណាស់ ដើរដោយគន្លងធម៌ម្យ៉ាងម្យ៉ាងដែរ!!

ក៖ ដោយសារឥឡូវអ្នកមីងក្មេងៗឥឡូវមិនបានទេបើជក់ គ្រឿងញៀន។

ខ៖ ហ្នឹងហើយ!!

ក៖ គេចាប់បានជាប់គុកនៅជិតផ្ទះរបស់ខ្ញុំអ្នកមីងណាស់ទើបតែការហើយបានតែ 1 ឆ្នាំកូនបានដូចតែមួយសោះហ្នឹងណាស់អាប្តីនិងណាស់ទៅរកស៊ីជួញដូរគ្រឿងញៀនផ្លូវគេចាប់ដាក់គុគបាត់ហើយ។

ខ៖ ហ្នឹងហើយ!!

ក៖ ហើយប្រពន្ធលេងបៀរ។ខ្ញុំ ឆ្ងល់ដល់ហើយហេតុអ្វីមិនព្រមដើរលើផ្លូវឲ្យតែល្អទៅហេតុអ្វី!! វេទនាណាស់!!

ខ៖ វេទនាណាស់!!វត្តថាកម្មវាទាញទៅ ហ្នឹងហើយ!!

ក៖ អញ្ចឹងអ្នកមីងកូនចៅសុទ្ធតែបានល្អទាំងអស់មានទេអ្នកមីង?

ខ៖ កូនចៅរបស់ខ្ញុំមិនអីទេ!!

ក៖
ចាំ!!!ចានិងហើយឥឡូវគេមានប្រពន្ធមានកូនទៅអ្នកនឹងរឹតតែធូរបន្តិចទៀតហើយដោយសារដឹងខុសដឹងត្រូវអ្នកមីងណោះ?

ខ៖ ហ្នឹងហើយ!!

ក៖
ចាំអញ្ចឹងអរគុណច្រើនអ្នកមានស្រការសម្ភាសន៍នៅក្នុងថ្ងៃនេះដែរខ្ញុំដឹងថាអ្វីទាំងអស់កូនចៅរបស់អ្នកមីងនឹងបានស្តាប់សំឡេងរបស់អ្នកមីងហើយក៏ដូចជាចង់សិក្សាប្រវត្តិប្រជាជនខ្មែរយើងអញ្ចឹងទៅណាស់អ្នកមីងហើយពួកយើងនឹងយកសំឡេងរបស់អ្នកមីងទៅដាក់នៅក្នុងវេបសាយរបស់សាលាដែលខ្ញុំបានធ្វើការឲ្យហើយគាត់នឹងរក្សាហើយនិងកូនចៅខ្មែរជំនាន់ក្រោយនិងបានដឹងអំពីជីវិតក៏ដូចជាប្រវត្តិប្រជាជនកម្ពុជាហើយខ្ញុំដឹងថារឿងមួយនេះវាសំខាន់ខ្លាំងបំផុតតែម្តងដោយសារពួកយើងមានសម្លេងស្តាប់ផ្ទាល់វាមិនមែនអានក្នុងសៀវភៅឬអ្វីទេតែយើងអាចស្តាប់សំឡេងរបស់អ្នកមីងផ្ទាល់អញ្ចឹងតែម្តងណាស់អ្នកមីងអញ្ចឹងអរគុណច្រើនសុខសប្បាយសុខភាពល្អ!!

ខ៖ ចាំ។